# ICNL

www.icnl.org
info@icnl.org

អត្ថបទវិភាគគតិយុត្តិ៖ **ព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ឆ្នាំ២០២៤

## សេចក្តីផ្តើម

នាពេលបច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជាកំពុងពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ("សេចក្តីព្រាងច្បាប់")។ សេចក្តីព្រាងច្បាប់នេះ មានគោលបំណងបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសបច្ចេកវិទ្យាព័ត៌មាន។ តបតាមសំណូមពរពីអង្គការដៃគូ មជ្ឈមណ្ឌល ICNL មានមោទកភាពនឹងចែករំលែកការវិភាគសេចក្តីព្រាងច្បាប់នេះ ដោយផ្តល់ជាអនុសាសន៍សម្រាប់កែសម្រួលសេចក្តីព្រាងច្បាប់ ក្នុងគោលបំណងការពារសេរីភាពបញ្ចេញមតិ និងសិទ្ធិឯកជនភាព ឱ្យកាន់តែប្រសើរជាងមុន ព្រមទាំងជួយសម្រាលក្តីបារម្ភពីលំហសេរីភាពពលរដ្ឋផ្សេងៗទៀត។

ទន្ទឹមនឹងការចែងពីដំណើរការនីតិវិធីគួរឱ្យស្ងើចសរសើរមួយចំនួននៅក្នុងសេចក្តីព្រាងច្បាប់នេះ ដូចជាការតម្រូវឱ្យមានដីកាតុលាការដើម្បីភ្ជាប់ទៅកាន់ប្រព័ន្ធកុំព្យូទ័រ និងទិន្នន័យកុំព្យូទ័រ និងការការពារសិទ្ធិក្នុងការតវ៉ានឹងសេចក្តីសម្រេចពីបញ្ហាបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដាក់ជូនក្រសួងមហាផ្ទៃ និងជាចុងក្រោយដាក់ទៅតុលាការ សេចក្តីព្រាងច្បាប់នេះក៏មានចែងពីបញ្ញត្តិមួយចំនួនដែលមិនមានអនុលោមភាពតាមច្បាប់អន្តរជាតិផងដែរ។ បញ្ហាទាំងនោះរួមមាន៖

- **ការរឹតត្បិតសេរីភាពបញ្ចេញមតិ**
    - ការកំណត់ថាការសម្លុត ការគំរាមកំហែង ការបំពាន និងការប្រមាថអ្នកដទៃជាបទឧក្រិដ្ឋ អាចដាក់កម្រិតដល់ការរិះគន់អាជ្ញាធរ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល
    - ការកំណត់ថាការបរិហារកេរ្តិ៍ជាបទឧក្រិដ្ឋ អាចរឹតត្បិតការរិះគន់បុគ្គលសាធារណៈនានា និង

INTERNATIONAL CENTER
FOR NOT-FOR-PROFIT LAW

1126 16th Street NW #400
Washington, DC 20036

  - ការកំណត់ថាការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយជាបទឧក្រិដ្ឋ អាចបំបិទមិនឱ្យមានការរិះគន់មន្ត្រីអាជ្ញាធរ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលបាន។

- **ការរឹតត្បិតទៅលើសិទ្ធិឯកជនភាព**
  - សិទ្ធិអំណាចទូលាយពេកក្នុងការឆែកឆេរ និងរឹបអូសរបស់មន្ត្រីនគរបាលយុត្តិធម៌ អាចផ្តល់សិទ្ធិអំណាចដល់អាជ្ញាធរក្នុងការតាមដានសំខាន់ៗ
  - ការពន្យារពេលដែលមិនកំណត់រយៈពេល នៃការចូលទៅកាន់ទិន្នន័យចរាចរណ៍ និងទិន្នន័យខ្លឹមសារ អាចផ្តល់សិទ្ធិអំណាចដល់អាជ្ញាធរក្នុងការតាមដានសង្គមស៊ីវិល និងបុគ្គលផ្សេងទៀតលើសពីការស៊ើបអង្កេតរកបទល្មើសណាមួយ
  - សិទ្ធិអំណាចទូលាយពេកក្នុងការចែកចាយទិន្នន័យ អាចផ្តល់ឆន្ទានុសិទ្ធិដល់អាជ្ញាធរក្នុងការតាមដានសង្គមស៊ីវិល និងបុគ្គលផ្សេងទៀត និង
  - កង្វះការការពារជាក់លាក់ចំពោះអ្នកផ្តល់ព័ត៌មាន (whistleblowers) ដែលជាបុគ្គលសំខាន់គិតគូរដល់សិទ្ធិទទួលបានព័ត៌មានរបស់សាធារណជន ដើម្បីជាផលប្រយោជន៍សាធារណៈ។

អត្ថបទវិភាគនេះ ធ្វើការប្រៀបធៀបសេចក្តីព្រាងច្បាប់នេះ ជាមួយនឹងច្បាប់អន្តរជាតិ ស្តង់ដារ និងការអនុវត្តល្អៗ ដែលទាក់ទងនឹងសេរីភាពបញ្ចេញមតិ សិទ្ធិឯកជនភាព និងសេរីភាពពលរដ្ឋពាក់ព័ន្ធផ្សេងទៀត។ អត្ថបទវិភាគនេះ មិនធ្វើការវិភាគលើគ្រប់បញ្ហាទាំងអស់នៅក្នុងសេចក្តីព្រាងច្បាប់នោះទេ។

## ច្បាប់អន្តរជាតិ

**សិទ្ធិសេរីភាពបញ្ចេញមតិ៖** មាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (កតិកាសញ្ញា ICCPR) ការពារសិទ្ធិសេរីភាពបញ្ចេញមតិ ដែលរាប់បញ្ចូលទាំងសិទ្ធិមានយោបល់ដោយគ្មានការរំខាន និងសេរីភាពស្វែងរក ទទួលបាន និងចែករំលែកព័ត៌មាន និងគំនិតគ្រប់រូបភាព ដោយគ្មានដែនកំណត់។[1]

រដ្ឋសមាជិកនៃកតិកាសញ្ញា ICCPR មានកាតព្វកិច្ចធានាសិទ្ធិសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋ។ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បានថ្លែងថា "រាល់ការរឹតត្បិតទៅលើ

[1] ព្រះរាជាណាចក្រកម្ពុជាចុះហត្ថលេខាលើកតិកាសញ្ញា ICCPR នៅឆ្នាំ១៩៩២

ប្រតិបត្តិការគេហទំព័រ ប្លុក (Blog) ឬប្រព័ន្ធអេឡិចត្រូនិចផ្សេងៗនៅលើប្រព័ន្ធអ៊ិនធើណិត ឬប្រព័ន្ធចែកចាយព័ត៌មានផ្សេងទៀត" ត្រូវតែអនុលោមតាមមាត្រា ១៩ នៃកតិកាសញ្ញា ICCPR ។[2]

ការរឹតត្បិតទៅលើការនិយាយស្តី និងការបញ្ចេញមតិ ដែលត្រូវបានធានានៅក្នុងមាត្រា ១៩ នៃកតិកាសញ្ញា ICCPR គឺជាបញ្ញត្តិស្របច្បាប់បាន លុះត្រាតែការរឹតត្បិតនោះបានឆ្លងកាត់ការធ្វើតេស្តបង្ករ បីចំណុច ដែលដកស្រង់ចេញពីមាត្រា ១៩ ជាមុនសិន ដូចខាងក្រោម៖

> (១) **គោលការណ៍នីត្យានុកូលភាព៖** ការរឹតត្បិត ត្រូវតែមានចែងយ៉ាងច្បាស់លាស់នៅក្នុងច្បាប់ ដែលអ្នកអានច្បាប់អាចងាយយល់ដឹងអំពីរបៀបដែលត្រូវអនុលោមតាមច្បាប់ និងផលវិបាកពីការបំពានច្បាប់
>
> (២) **គោលការណ៍ភាពស្របច្បាប់៖** ការរឹតត្បិតត្រូវតែមានគោលបំណងមួយក្នុងចំណោមគោលបំណងទាំងអស់ដែលមានចែងនៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១៩ នៃកតិកាសញ្ញា ICCPR ដូចជា៖ (i) ការពារសិទ្ធិ ឬកិត្តិសព្ទរបស់អ្នកដទៃ (ii) ការពារសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬសុខមាលភាព ឬសីលធម៌សាធារណៈ និង
>
> (៣) **គោលការណ៍សមាមាត្រ៖** ការរឹតត្បិតត្រូវតែបញ្ជាក់បង្ហាញថាជាមធ្យោបាយរឹតត្បិតតិចតួចបំផុត ដែលត្រូវការដើម្បីសម្រេចបាននូវគោលដៅដែលបានលើកឡើង។[3]

**សិទ្ធិឯកជនភាព៖** មាត្រា ១៧ នៃកតិកាសញ្ញា ICCPR ការពារសិទ្ធិឯកជនភាព។ ការការពារសិទ្ធិឯកជនភាព ជារឿងសំខាន់ដើម្បីទទួលបានពេញលេញនូវសិទ្ធិសេរីភាពបញ្ចេញមតិ។ ការជ្រៀតជ្រែកមិនត្រឹមត្រូវទៅលើឯកជនភាពរបស់បុគ្គល អាចមានឥទ្ធិពលមិនល្អទៅលើឆន្ទៈក្នុងការ

---

[2] កថាខណ្ឌទី ៤៣ នៃសេចក្តីពន្យល់ទូទៅលេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្ស៖ "*មាត្រា ១៩៖ សេរីភាពបញ្ចេញមតិ និងយោបល់*" ឯកសាររបស់អង្គការសហប្រជាជាតិ លេខ CCPR/C/GC/34 (ឆ្នាំ ២០១១)

[3] ជាឧទាហរណ៍ សូមមើល កថាខណ្ឌទី ៦៩ នៃ "*របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសេរីភាពបញ្ចេញមតិ និងយោបល់*" របស់លោក Frank La Rue ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/17/27 (ឆ្នាំ២០១១)

អភិវឌ្ឍ ការផ្លាស់ប្តូរ និងការទទួលបានគំនិត។[4] ការដាក់កម្រិតទៅលើសិទ្ធិឯកជនភាព ក៏ត្រូវតែឆ្លងកាត់ការធ្វើតេស្តត្រួតគ្នាបីចំណុចខាងលើផងដែរ ដោយគោលបំណងស្របច្បាប់នៃការរឹតត្បិតទៅលើសិទ្ធិឯកជនភាព គឺដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខមាលភាព ឬសីលធម៌សាធារណៈ ព្រមទាំងសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។[5]

## បញ្ហា

### ការកំណត់ថាការសម្លុត ការគំរាមកំហែង ការបំពាន និងការប្រមាថអ្នកដទៃ ជាបទឧក្រិដ្ឋ

**បញ្ហា៖** ការហាមឃាត់ចំពោះការសម្លុត ការគំរាមកំហែង ឬការបំពានបុគ្គលដទៃ[6] ដែលមានចែងនៅក្នុងមាត្រា ៤២ នៃសេចក្តីព្រាងច្បាប់ និងការហាមឃាត់មិនឱ្យប្រើប្រាស់ភាសាប្រមាថ មើលងាយ ឬមិនពិរោះពិសា[7] ដែលមានចែងនៅក្នុងមាត្រា ៤៤ នៃសេចក្តីព្រាងច្បាប់ រឹតត្បិតទៅលើសេរីភាពបញ្ចេញមតិដែលមិនអាចទទួលយកបាន។ ការហាមឃាត់ទាំងនេះ ជាការដាក់កម្រិតទូលាយពេកទៅលើសេរីភាពបញ្ចេញមតិ ដែលអាចរឹតត្បិតទៅលើការរិះគន់រដ្ឋាភិបាល ឬគោលនយោបាយរបស់រដ្ឋាភិបាលបាន។

**ការវិភាគ៖** ថ្វីត្បិតតែរដ្ឋាភិបាលអាចមានផលប្រយោជន៍ស្របច្បាប់ក្នុងការដាក់បញ្ញត្តិទៅលើការបំពានតាមអនឡាញ ប៉ុន្តែការរឹតត្បិតទៅលើសេរីភាពបញ្ចេញមតិ អាចជារឿងស្របច្បាប់បាន លុះត្រាតែការរឹតត្បិតទាំងនោះឆ្លងកាត់ការធ្វើតេស្ត ៣ ចំណុចស្របតាមមាត្រា ១៩ នៃកតិកាសញ្ញា ICCPR ។ វាក្យស័ព្ទ "សម្លុត" "គំរាមកំហែង" "បំពាន" "ប្រមាថ" "មើលងាយ" និង "ឈ្លើយ" មិនមានអត្ថន័យច្បាស់លាស់គ្រប់គ្រាន់ក្នុងការអនុញ្ញាតឱ្យបុគ្គលណាម្នាក់យល់ដឹងថាការនិយាយស្តី ឬអត្តចរិកបែបណាត្រូវបានហាមឃាត់នោះទេ ដែលជាហេតុធ្វើឱ្យបញ្ញត្តិទាំងនេះមិនស្ថិតក្នុងគោលការណ៍នីត្យានុកូលភាពនោះទេ។ លើសពីនេះ ច្បាប់អន្តរជាតិការពារការនិយាយស្តី សូម្បីតែ "ក្នុង

---

[4] សូមមើល ផ្នែក "ក" ("អន្តរទំនាក់ទំនងរវាងសិទ្ធិឯកជនភាព និងសេរីភាពបញ្ចេញមតិ និងយោបល់") នៃ *"របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសេរីភាពបញ្ចេញមតិ និងយោបល់"* របស់លោក Frank La Rue ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40 (ឆ្នាំ២០១៣)។

[5] សូមមើល ផ្នែក "ខ" ("ការដាក់កម្រិតដែលអាចទទួលយកបានទៅលើឯកជនភាព និងសេរីភាពបញ្ចេញមតិ") នៃ *"របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសេរីភាពបញ្ចេញមតិ និងយោបល់"* របស់លោក Frank La Rue ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40 (ឆ្នាំ២០១៣)។

[6] មាត្រា ៤២ នៃសេចក្តីព្រាងច្បាប់ កំណត់ថាការបំពានដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន ជាបទឧក្រិដ្ឋ នៅពេលណាដែលអំពើនោះបង្កដោយចេតនាជាការសម្លុត ការគំរាមកំហែង ឬការបំពានដល់បុគ្គលដទៃ ដោយប្រើមធ្យោបាយពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន។

[7] មាត្រា ៤៤ នៃសេចក្តីព្រាងច្បាប់ ចែងអំពីអំពើប្រមាថ ដោយកំណត់ថា "ការប្រើប្រាស់ភាសាប្រមាថ មើលងាយ ឬឈ្លើយ តាមរយៈបច្ចេកវិទ្យាព័ត៌មាន ដោយមិនដាក់ការទទួលខុសត្រូវទៅលើសកម្មភាពណាមួយ" ជាបទឧក្រិដ្ឋ។

ន័យការវាយប្រហារខ្លាំងៗ″ ឬការនិយាយស្តីបែបប្រមាថក្តី។[8] មាត្រា ៤៤ នៃសេចក្តីព្រាងច្បាប់ហាក់ដូចជាកំណត់ថាសូម្បីតែការនិយាយស្តីមើលងាយបែបស្រាលៗក៏ជាបទឧក្រិដ្ឋដែរ ដែលការកំណត់បែបនេះបំពាននឹងស្តង់ដារនេះ។[9]

ដោយគ្មានការផ្តល់និយមន័យបន្ថែមទាក់ទងនឹងវាក្យស័ព្ទទាំងនេះ អាជ្ញាធរមានឆន្ទានុសិទ្ធិទូលាយក្នុងការកំណត់ថាបុគ្គលណាម្នាក់បានសម្លុត គំរាមកំហែង បំពាន ឬមើលងាយបុគ្គលម្នាក់ផ្សេងទៀត។ ជាឧទាហរណ៍ អាជ្ញាធរអាចចាប់ខ្លួនសមាជិកគណបក្សប្រឆាំង បុគ្គលិកអង្គការសង្គមស៊ីវិល ឬបុគ្គលឯកជនណាដែលទាមទារឱ្យតំណាងរដ្ឋាភិបាលលាលែងពីតំណែង ដោយអាជ្ញាធរអាចធ្វើការបកប្រែថាការទាមទារនោះជាការសម្លុត ឬគំរាមកំហែងបាន។ ការអនុវត្តច្បាប់បែបនេះ អាចបំបិទសម្លេងប្រឆាំង និងសម្លេងរិះគន់ផ្សេងទៀតបាន។ ដើម្បីបង្រួមវិសាលភាពនៃបទប្បញ្ញត្តិទាំងនេះ គួរតែកំណត់ថា ប្រសិនបើសកម្មភាពណាដែលបណ្តាលឱ្យមានព្យសនកម្មដល់រូបរាងកាយ ឬផ្លូវចិត្តរបស់បុគ្គលណាម្នាក់ដោយផ្ទាល់ ត្រូវចាត់ទុកថាជាបទឧក្រិដ្ឋ។

ច្បាប់អន្តរជាតិ តម្រូវថាបុគ្គលសាធារណៈត្រូវចេះអនុគ្រោះ អត់ធ្មត់ខ្លាំងនឹងការរិះគន់ធ្ងន់ៗ ជាងពលរដ្ឋសាមញ្ញធម្មតា។[10] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ពន្យល់ថា ‶អង្គហេតុធម្មតាដែលបង្កើតជាមតិយោបល់ ត្រូវបានចាត់ទុកថាជាការប្រមាថបុគ្គលសាធារណៈ គឺមិនគ្រប់គ្រាន់នោះទេក្នុងការបញ្ជាក់អះអាងឱ្យផ្តន្ទាទោសនោះ″ និងកត់សម្គាល់យ៉ាងច្បាស់ថា ‶គ្រប់បុគ្គលសាធារណៈ.... គឺជាកម្មវត្ថុយ៉ាងស្របច្បាប់សម្រាប់ទទួលការរិះគន់ និងការប្រឆាំងបែបនយោបាយ″។ សេចក្តីព្រាងច្បាប់នេះ ត្រូវរួមបញ្ចូលភាសាបង្ការមិនឱ្យអាជ្ញាធរប្រើបញ្ញត្តិទាំងនេះដើម្បីបំបិទមិនឱ្យមានការរិះគន់ទៅលើបុគ្គលសាធារណៈ។

---

[8] កថាខណ្ឌទី ១១ នៃសេចក្តីពន្យល់ទូទៅលេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្ស៖ ‶*មាត្រា ១៩៖ សេរីភាពបញ្ចេញមតិ និងយោបល់*″ ឯកសាររបស់អង្គការសហប្រជាជាតិ លេខ CCPR/C/GC/34 (ឆ្នាំ ២០១១)

[9] ជាការគួរឱ្យកត់សម្គាល់ថា ផ្នែកទី ២ នៃក្រមព្រហ្មទណ្ឌ បានកំណត់ការប្រមាថនៅទីសាធារណៈ ឬវេទិកាសាធារណៈ ថាជាបទឧក្រិដ្ឋរួចទៅហើយ។ ហេតុដូច្នេះ ជាការមិនច្បាស់ថាហេតុអ្វីមាត្រា ៤៤ នៃសេចក្តីព្រាងច្បាប់នេះ ត្រូវមានជាចាំបាច់ ខណៈដែលការនិយាយស្តីបែបប្រមាថនេះ ត្រូវបានហាមឃាត់រួចទៅហើយនោះ (ទំនងជាផ្ទុយនឹងច្បាប់អន្តរជាតិ)។

[10] សូមមើលកថាខណ្ឌទី ៣៨ នៃសេចក្តីពន្យល់ទូទៅលេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្ស៖ ‶*មាត្រា ១៩៖ សេរីភាពបញ្ចេញមតិ និងយោបល់*″ ឯកសាររបស់អង្គការសហប្រជាជាតិ លេខ CCPR/C/GC/34 (ឆ្នាំ ២០១១)។ សូមមើលទំព័រទី ១៨ នៃ″*របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសេរីភាពបញ្ចេញមតិ និងយោបល់*″ ដោយ *Abid Hussain* ឯកសាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ ដែលបានដាក់ជូន អនុលោមតាមសេចក្តីសម្រេចរបស់គណៈកម្មការ លេខ 1999/36, E/CN.4/2000/63 (ឆ្នាំ២០០០)។

**អនុសាសន៍៖** គួរកែសម្រួលមាត្រា ៤២ នៃសេចក្តីព្រាងច្បាប់ ថាប្រសិនបើការសម្លុត ការគំរាមកំហែង ឬការបំពានណាដែលបណ្តាលឱ្យមានព្យសនកម្មដល់រូបរាងកាយ ឬផ្លូវចិត្ត ដោយផ្ទាល់ត្រូវចាត់ទុកថាជាបទឧក្រិដ្ឋ។ នៅកថាខណ្ឌចុងក្រោយនៃមាត្រា ៤២ គួរបន្ថែមកថាខណ្ឌមួយដែលអនុញ្ញាតឱ្យមានការរិះគន់មន្ត្រីរាជការ គោលនយោបាយរដ្ឋាភិបាល និងបុគ្គលសាធារណៈផ្សេងៗជាដើម។ គួរលុបមាត្រា ៤៤ នៃសេចក្តីព្រាងច្បាប់ចេញ។

## ការកំណត់ថាការបរិហារកេរ្តិ៍ជាបទឧក្រិដ្ឋ

**បញ្ហា៖** មាត្រា ៤៣ នៃសេចក្តីព្រាងច្បាប់ កំណត់ថាការបរិហារកេរ្តិ៍តាមអនឡាញជាបទឧក្រិដ្ឋ។[11] ការកំណត់បែបនេះ អាចបំបិទមិនឱ្យមានការមិនយល់ស្រប និងបង្កើតបានជាការរឹតត្បិតដែលមិនអាចទទួលយកបានទៅលើសេរីភាពបញ្ចេញមតិ។[12]

**ការវិភាគ៖** រដ្ឋសមាជិកនៃកតិកាសញ្ញា ICCPR គួរតែគិតពិចារណាឱ្យបានច្បាស់ពីការមិនត្រូវកំណត់ថាការបរិហារកេរ្តិ៍ជាបទឧក្រិដ្ឋ និងអនុវត្តតែក្រមព្រហ្មទណ្ឌទៅលើបទបរិហារកេរ្តិ៍ដែលធ្ងន់ធ្ងរបំផុតប៉ុណ្ណោះបានហើយ។[13] ការផ្តន្ទាទោសដាក់ពន្ធនាគារចំពោះបទបរិហារកេរ្តិ៍ មិនស្ថិតក្នុងគោលការណ៍សមាមាត្រនោះទេ ដោយហេតុថាវាមិនមែនជាមធ្យោបាយរឹតត្បិតតិចតួចបំផុតដែលប្រើសម្រាប់ការពារកិត្តិស័ព្ទរបស់បុគ្គលនោះទេ។ មធ្យោបាយរឹតត្បិតតិចជាងនេះ អាចជាការអនុវត្តទោសរដ្ឋប្បវេណីចំពោះបទបរិហារកេរ្តិ៍ ដែលអាចរួមបញ្ចូលការអនុញ្ញាតឱ្យតុលាការបង្គាប់បញ្ជាជនល្មើសចេញសេចក្តីកែសម្រួលព័ត៌មានក្លែងក្លាយ ឬបង់ពិន័យជាប្រាក់សម្រាប់ជាសំណងខូចខាតដល់ជនរងគ្រោះ ក្នុងករណីមានព្យសនកម្មអាចវាស់វែងបាន។ ការផាកពិន័យដែលអាចទទួលយកបានជាច្រើនប្រភេទនៅក្នុងសេចក្តីព្រាងច្បាប់ គួរតែមានសង្គតភាពជាមួយនឹងបទបរិហារកេរ្តិ៍ក្រោមក្រមព្រហ្មទណ្ឌ (ជាអាទិ៍ គួរតែកំណត់ប្រាក់ពិន័យចាប់ពី ១០០ ០០០ (មួយសែន) ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ជំនួសឱ្យការកំណត់ប្រាក់ពិន័យចាប់ពី ២ ០០០ ០០០ (ពីរលាន) ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល។)[14]

---

[11] មាត្រា ៤៣ នៃសេចក្តីព្រាងច្បាប់កំណត់ថា "ការទាមទារដែលបំផ្លើស ឬការដាក់ការទទួលខុសត្រូវដែលមិនស្មោះត្រង់ចំពោះអំពើណាមួយដែលប៉ះពាល់ដល់កិត្តិយស ឬកិត្តិស័ព្ទនៃបុគ្គល ឬនៃស្ថាប័ន" ជាបទឧក្រិដ្ឋ។

[12] ជាការគួរឱ្យកត់សម្គាល់ថា មាត្រា ៣០៥-៣០៦ នៃក្រមព្រហ្មទណ្ឌ បានចែងថាការបរិហារកេរ្តិ៍ជាបទល្មើសរួចទៅហើយ ដោយរាប់បញ្ចូលទាំងការបរិហារកេរ្តិ៍តាមសារព័ត៌មានផងដែរ។ ហេតុដូច្នេះ ជាការមិនច្បាស់ថាហេតុអ្វី មាត្រា ៤៣ នៃសេចក្តីព្រាងច្បាប់ជារឿងចាំបាច់ត្រូវមាននោះទេ។ ដូចបានពន្យល់បកស្រាយនៅក្នុងអត្ថបទវិភាគនេះ បទល្មើសទាំងពីរទំនងជាអាចផ្ទុយនឹងច្បាប់អន្តរជាតិ។

[13] កថាខណ្ឌទី ៤៧ នៃសេចក្តីពន្យល់ទូទៅលេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្ស៖ "*មាត្រា ១៩៖ សេរីភាពបញ្ចេញមតិ និងយោបល់*" ឯកសាររបស់អង្គការសហប្រជាជាតិ CCPR/C/GC/34 (ឆ្នាំ ២០១១)

[14] សូមមើលមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ

ហានិភ័យនៃការផ្តន្ទាទោសដាក់ពន្ធនាគារ និងការផ្តន្ទាទោសព្រហ្មទណ្ឌផ្សេងទៀតចំពោះបទបរិហារកេរ្តិ៍ ក្រោមសេចក្តីព្រាងច្បាប់នេះ អាចមានឥទ្ធិពលបំបិទសម្លេងបុគ្គលបាន ដោយហេតុថាបុគ្គលនឹងខ្លាចរអារថាអាជ្ញាធរអាចនឹងអនុវត្តការផ្តន្ទាទោសធ្ងន់ៗ ដើម្បីវាយបកទៅលើការបញ្ចេញមតិរិះគន់។ ចំពោះរដ្ឋសមាជិកដែលកំណត់ថាការបរិហារកេរ្តិ៍ជាបទល្មើសដែលត្រូវផ្តន្ទាទោស និងដើម្បីកម្រិតពីហានិភ័យដែលថាអាជ្ញាធរបំពានច្បាប់បរិហារកេរ្តិ៍ក្នុងគោលបំណងបំបិទសម្លេងរិះគន់ ច្បាប់នៃរដ្ឋសមាជិកនោះគួរតែអនុញ្ញាតឱ្យជនជាប់ចោទអាចការពារខ្លួនបាន តាមការខំប្រឹងប្រែងដោយសមហេតុផលរបស់គាត់ក្នុងការបញ្ជាក់ពីការពិតថាអំពើ/សកម្មភាពនោះ ធ្វើឡើងដើម្បីបម្រើឱ្យផលប្រយោជន៍សាធារណៈ។[15] ជាឧទាហរណ៍ តុលាការសិទ្ធិមនុស្សអឺរ៉ុប បានលើកឡើងថា កាសែត និងអ្នកនិពន្ធមិនត្រូវទទួលខុសត្រូវចំពោះការបរិហារកេរ្តិ៍ ដោយសារតែបានបោះពុម្ពផ្សាយសេចក្តីថ្លែងក្លែងក្លាយថាសមាជិកនាវាប្រមាញ់សត្វភេសមុទ្របានប្រព្រឹត្តិបទឧក្រិដ្ឋនោះទេ។ កាសែត និងអ្នកនិពន្ធបានរាយការណ៍ដោយសុទ្ធចិត្ត ក្នុងន័យបម្រើឱ្យផលប្រយោជន៍សាធារណៈ ហើយដែលផលប្រយោជន៍សាធារណៈនេះត្រូវបានគាំទ្រដោយរបាយការណ៍របស់ក្រសួងនេសាទដែលមានកម្រិតគួរឱ្យជឿទុកចិត្តបានខ្ពស់។[16] ការបរិហារកេរ្តិ៍ មិនគួរត្រូវបានអនុវត្តទៅលើទម្រង់នៃការបញ្ចេញមតិដែលមិនមែនជាកម្មវត្ថុសម្រាប់ពិនិត្យផ្ទៀងផ្ទាត់ ដូចជាវិចារណកថាប្រឆាំងនឹងអត្ថបទសារព័ត៌មានដែលបានរាយការណ៍ព្រឹត្តការណ៍ថ្មីមួយ។ លើសពីនេះ បទបរិហារកេរ្តិ៍ ត្រូវមានធាតុផ្សំមួយ ដែលថាជនជាប់ចោទបានធ្វើសេចក្តីថ្លែងដោយមានចេតនាបង្កជាព្យសនកម្មដល់កិត្តិយស ឬកិត្តិស័ព្ទរបស់បុគ្គល។[17]

---

[15] កថាខណ្ឌទី ៤៧ នៃសេចក្តីពន្យល់ទូទៅលេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្ស៖ *មាត្រា ១៩៖ សេរីភាពបញ្ចេញមតិ និងយោបល់* ឯកសាររបស់អង្គការសហប្រជាជាតិ CCPR/C/GC/34 (ឆ្នាំ ២០១១)។ សូមមើលកថាខណ្ឌទី៥១-៥២ នៃឯកសាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមនៃអង្គការសហប្រជាជាតិស្តីពី *សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រួមបញ្ចូលសំណួរអំពីសេរីភាពបញ្ចេញមតិ* (ខែមករា ឆ្នាំ២០០០) លេខ E/CN.4/2000/63 អាចរកមើលបានតាមរយៈ https://documents.un.org/doc/undoc/gen/g00/102/59/pdf/g0010259.pdf?token=oj63GMbuve9pIZqvgV&fe=true ។ បញ្ហាគឺស្ថិតនៅលើផលប្រយោជន៍សាធារណៈ ប្រសិនបើពាក់ព័ន្ធនឹងបុគ្គលសាធារណៈ និងមន្ត្រីរាជការ នយោបាយ សុខមាលភាព និងសុវត្ថិភាពសាធារណៈ ការអនុវត្តច្បាប់ និងការគ្រប់គ្រងវិស័យយុត្តិធម៌ ផលប្រយោជន៍អ្នកប្រើប្រាស់ និងសង្គម បរិស្ថាន បញ្ហាសេដ្ឋកិច្ច ការប្រើអំណាច និងសិល្បៈ និងវប្បធម៌។ ចំណាំនៅជើងទំព័រ (Footnote) លេខ ៩ នៃ មាត្រា ១៩ ស្តីពីការឱ្យនិយមន័យការបរិហារកេរ្តិ៍៖ គោលការណ៍ស្តីពីសេរីភាពបញ្ចេញមតិ និងការការពារកិត្តិស័ព្ទ (ខែកក្កដា ឆ្នាំ២០០០) អាចរកមើលបានតាមរយៈ https://www.article19.org/wp-content/uploads/2018/02/defining-defamation.pdf

[16] សូមមើលពាក្យសុំលេខ 21980/93 រឿងក្តីរវាង Bladet Tromso និង Stensass ជាមួយនឹងប្រទេសណ័រវេ (ចុះខែឧសភា ឆ្នាំ ១៩៩៩) របស់តុលាការសិទ្ធិមនុស្សអឺរ៉ុប។ សម្រាប់សេចក្តីសង្ខេបរឿង សូមមើលឯកសាររបស់មហាវិទ្យាល័យកូឡុំប៊ី ស្តីពីរឿងក្តី "Bladet Tromso និង Stensass ជាមួយនឹងប្រទេសណ័រវេ" ដែលអាចរកមើលបានតាមរយៈ https://globalfreedomofexpression.columbia.edu/cases/bladet-tromso-and-stensaas-v-norway/

[17] កថាខណ្ឌទី ៤៧ នៃសេចក្តីពន្យល់ទូទៅលេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្ស៖ "*មាត្រា ១៩៖ សេរីភាពបញ្ចេញមតិ និងយោបល់*" ឯកសាររបស់អង្គការសហប្រជាជាតិ CCPR/C/GC/34 (ឆ្នាំ ២០១១)។

ជាចុងក្រោយ ស្ថាប័នសាធារណៈមិនគួរប្ដឹងផ្ដល់ពីការបរិហារកេរ្តិ៍នោះទេ។[18] ដូចគ្នានេះដែរ ក្រោមច្បាប់អន្តរជាតិ ការបរិហារកេរ្តិ៍មិនអាចជាបទឧក្រិដ្ឋឡើយ ប្រសិនបើបរិហារកេរ្តិ៍ធ្វើឡើងទៅលើវត្ថុ ឬនិមិត្តសញ្ញា។ វត្ថុ និងនិមិត្តសញ្ញា មិនដូចជាមនុស្សលោកយើងនោះទេ ពោលគឺមិនមាន "កិត្តិស័ព្ទ" ដែលត្រូវបានការពារដោយច្បាប់បរិហារកេរ្តិ៍នោះទេ។ គោលបំណងនៃច្បាប់បរិហារកេរ្តិ៍ គឺការពារកិត្តិស័ព្ទរបស់បុគ្គល និងមិនបង្ការមិនឱ្យមានការរិះគន់រដ្ឋាភិបាល អាជ្ញាធរផ្សេងៗ ឬទស្សនៈទាននោះដែរ។[19]

**អនុសាសន៍៖** គួរលុបចោលមាត្រា ៤៣ នៃសេចក្ដីព្រាងច្បាប់ ដោយហេតុថាការបរិហារកេរ្តិ៍ ត្រូវបានចែងថាជាបទល្មើសរួចទៅហើយនៅក្នុងក្រមព្រហ្មទណ្ឌ។ ប្រសិនបើនៅតែរក្សាទុកមាត្រា ៤៣ នៅក្នុងសេចក្ដីព្រាងច្បាប់នេះដដែល គួរតែលុបចោលការផ្ដន្ទាទោសដាក់ពន្ធនាគារចេញ ហើយជំនួសដោយការចែងថា តុលាការអាចបង្គាប់បញ្ជាឱ្យជនជាប់ចោទចេញសេចក្ដីកែតម្រូវការថ្លែងក្លែងក្លាយ ឬបង់ជាប្រាក់ពិន័យចំនួន ១០០ ០០០ (មួយសែន) ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល អាស្រ័យទៅតាមស្ថានទម្ងន់នៃព្យសនកម្មដែលបង្កដោយសេចក្ដីថ្លែងនោះ។ បន្ថែមពីលើការការពារនៃការកំណត់ថាការបរិហារកេរ្តិ៍ជាបទឧក្រិដ្ឋ ប្រសិនបើជនជាប់ចោទបានខំប្រឹងប្រែងដោយសមហេតុផលក្នុងការបញ្ជាក់ពីការពិតនៃរឿងហេតុកើតឡើងថាធ្វើឡើងដើម្បីបម្រើផលប្រយោជន៍សាធារណៈ។ ជាចុងក្រោយ ការចែងក្នុងមាត្រា ៤៣ នៃសេចក្ដីព្រាងច្បាប់នេះ ថា "ការទាមទារពន្លើស ឬការបន្ទោសមិនស្មោះត្រង់" គួរតម្រូវថាធ្វើឡើងដោយមានគំនិតព្យាបាទ ឬទុច្ចរិត។

## ការកំណត់ថាការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ ជាបទឧក្រិដ្ឋ

**បញ្ហា៖** មាត្រា ៤៩ នៃសេចក្ដីព្រាងច្បាប់ ហាមឃាត់ការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយណាដែលប៉ះពាល់ដោយចេតនាដល់ផលប្រយោជន៍សាធារណៈយ៉ាងខ្លាំង និងផ្ដល់ឆន្ទានុសិទ្ធិយ៉ាងទូលាយដល់

---

[18] សូមមើលកថាខណ្ឌទី៥០ នៃឯកសាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមនៃអង្គការសហប្រជាជាតិស្ដីពី *សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រួមបញ្ចូលសំណួរអំពីសេរីភាពបញ្ចេញមតិ* (ខែមករា ឆ្នាំ២០០០) លេខ E/CN.4/2000/63 អាចរកមើលបានតាមរយៈ https://documents.un.org/doc/undoc/gen/g00/102/59/pdf/g0010259.pdf?token=oj63GMbuve9pIZqvgV&fe=true

[19] សូមមើលកថាខណ្ឌទី៥២ នៃឯកសាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមនៃអង្គការសហប្រជាជាតិស្ដីពី *សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រួមបញ្ចូលសំណួរអំពីសេរីភាពបញ្ចេញមតិ* (ខែមករា ឆ្នាំ២០០០) លេខ E/CN.4/2000/63 អាចរកមើលបានតាមរយៈ https://documents.un.org/doc/undoc/gen/g00/102/59/pdf/g0010259.pdf?token=oj63GMbuve9pIZqvgV&fe=true ។ សូមមើលផងដែរ កថាខណ្ឌទី ៤១ នៃឯកសាររបស់មហាសន្និបាតអង្គការសហប្រជាជាតិស្ដីពី *"ការលើកស្ទួយ និងការការពារសេរីភាពបញ្ចេញមតិ និងយោបល់"* (ចុះខែកញ្ញា ឆ្នាំ២០១៦) លេខ A/71/373 (បានពន្យល់ថាសេរីភាពបញ្ចេញមតិការពារបុគ្គលដែលកាន់ ឬបង្ហាញពីជំនឿ ជាជាងជំនឿ ឬប្រព័ន្ធជំនឿផ្ទាល់)។

រដ្ឋាភិបាលក្នុងការកំណត់ថាបុគ្គលណាម្នាក់បានចែករំលែកព័ត៌មានដែលហាមឃាត់នោះ។[20] បញ្ញត្តិនេះអាចមានឥទ្ធិពលបំបិទសម្លេងសង្គមស៊ីវិល និងសាធារណជនក្នុងទ្រង់ទ្រាយធំ។

**ការវិភាគ៖** ការកំណត់ថាការចែកចាយព័ត៌មានក្លែងក្លាយជាបទឧក្រិដ្ឋ មិនមានភាពស៊ីសង្វាក់ជាមួយនឹងស្តង់ដារអន្តរជាតិសម្រាប់ការរឹតត្បិតសេរីភាពបញ្ចេញមតិ និងគួរតែលុបចោល។[21] ច្បាប់ដែលរឹតត្បិតមាតិកា "ក្លែងក្លាយ" អាចបំបាក់ទឹកចិត្តសារព័ត៌មានឯករាជ្យ បង្អារដល់ការជជែកវែកញែកជាសាធារណៈ និងធ្វើឱ្យគណនេយ្យភាពរដ្ឋាភិបាល និងសាធារណៈចុះទន់ខ្សោយ នៅពេលដែលទស្សនៈសំខាន់ៗត្រូវបានចាត់ទុកថាក្លែងក្លាយ។

មាត្រា ៤៩ នៃសេចក្តីព្រាងច្បាប់មិនមែនជាការរឹតត្បិតដែលអាចទទួលយកបានទៅលើសេរីភាពបញ្ចេញមតិក្រោមច្បាប់អន្តរជាតិនោះទេ។ បញ្ញត្តិនេះមិនស្របនឹងគោលការណ៍នីត្យានុកូលភាពដោយហេតុថាពាក្យថា "ព័ត៌មានក្លែងក្លាយ" មិនត្រូវបានផ្តល់និយមន័យឱ្យបានច្បាស់លាស់ ដែលធ្វើឱ្យអ្នកអានច្បាប់មិនដឹងថានៅពេលណាដែលសេចក្តីថ្លែងអាចត្រូវបានចាត់ទុកថា "ក្លែងក្លាយ" នោះទេ។ លើសពីនេះ វាមិនច្បាស់ថានៅពេលណាដែលកំណត់ថាសេចក្តីថ្លែងអាច "ប៉ះពាល់ដល់ការការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយបណ្តាប្រទេសដទៃ សេដ្ឋកិច្ច សណ្តាប់ធ្នាប់សាធារណៈ ឬបង្កឱ្យមានការប្រកាន់ជាតិសាសន៍ ឬប៉ះពាល់ដល់វប្បធម៌ប្រពៃណីជាតិ..."។ ភាពមិនច្បាស់លាស់នៃបញ្ញត្តិនេះ ផ្តល់ឆន្ទានុសិទ្ធិទូលាយដល់អាជ្ញាធរក្នុងការកំណត់ថាបុគ្គលណាម្នាក់បានផ្សព្វផ្សាយព័ត៌មាន "ក្លែងក្លាយ" ដែលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ និងបានប្រព្រឹត្តបទល្មើសក្រោមសេចក្តីព្រាងច្បាប់នេះ។ ជាឧទាហរណ៍ ប្រសិនបើសេដ្ឋវិទូម្នាក់ចែករំលែកការស្រាវជ្រាវ ថាអត្រាកំណើនផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេសកម្ពុជានឹងកើនឡើង ៥% នាឆ្នាំក្រោយ ក៏ប៉ុន្តែក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បែរជារាយការណ៍ថាអត្រាកំណើនផលិតផលក្នុងស្រុកសរុប (GDP) នឹងកើនឡើង ៧% ទៅវិញ។ ហេតុនេះអាជ្ញាធរអាចអះអាងថាសេដ្ឋវិទូម្នាក់នោះមានចេតនាផ្សព្វផ្សាយព័ត៌មាន "ក្លែងក្លាយ" ដែលធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ច

---

[20] មាត្រា ៤៩ នៃសេចក្តីព្រាងច្បាប់ចែងថា "ជនណាដែលផ្សព្វផ្សាយ ឬចែកចាយព័ត៌មានក្លែងក្លាយ តាមរយៈបច្ចេកវិទ្យាព័ត៌មាន និងមានចេតនាបង្កឱ្យមានការអន្តរាយដល់ការការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយនឹងបណ្តាប្រទេសដទៃ សេដ្ឋកិច្ច សណ្តាប់ធ្នាប់សាធារណៈ ឬបង្កឱ្យមានការរើសអើង ឬប៉ះពាល់ដល់វប្បធម៌ប្រពៃណី" ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់។

[21] កថាខណ្ឌទី ២(ក) នៃ *សេចក្តីប្រកាសរួមស្តីពី "ព័ត៌មានក្លែងក្លាយ" ការឱ្យព័ត៌មានខុស និងការឃោសនា* លេខ FOM.GAL/3/17 (ឆ្នាំ២០១៧) របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសេរីភាពបញ្ចេញមតិ និងយោបល់ , អ្នកតំណាងសេរីភាពសារព័ត៌មាននៃអង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE), អ្នករាយការណ៍ពិសេសស្តីពីសេរីភាពបញ្ចេញមតិ នៃអង្គការបណ្តាប្រទេសនៅទ្វីបអាមេរិក (OAS) និងអ្នករាយការណ៍ពិសេសស្តីពីសេរីភាពបញ្ចេញមតិ និងការទទួលបានព័ត៌មាននៃគណៈកម្មការអាហ្វ្រិកទទួលបន្ទុកសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន (ACHPR)

របស់ប្រទេសកម្ពុជា ពោលគឺរំលោភបំពាននឹងសេចក្តីព្រាងច្បាប់នេះ។ ការបកស្រាយបញ្ញត្តិបែបនេះ អាចនាំឱ្យថមថយ នូវការស្រាវជ្រាវឯករាជ្យអំពីបញ្ហាដែលទាក់ទងនឹងប្រទេសកម្ពុជាបាន។

មាត្រា ៤៩ នៃសេចក្តីព្រាងច្បាប់ ក៏មិនបំពេញតាមគោលការណ៍សមាមាត្រ ដោយសារការកំណត់ព័ត៌មានក្លែងក្លាយថាជាបទឧក្រិដ្ឋ មិនមែនជាមធ្យោបាយរឹតត្បិតតិចតួចបំផុតក្នុងការការពារផលប្រយោជន៍សាធារណៈនោះទេ។ ជាឧទាហរណ៍ មធ្យោបាយផ្សេង និងមិនសូវរឹតត្បិតក្នុងការការពារសិទ្ធិនិងកិត្តិស័ព្ទរបស់អ្នកដទៃ អាចជាការប្រើច្បាប់បរិហារកេរ្តិ៍តាមវិធានការរដ្ឋប្បវេណី ជាជាងការប្រើវិធានការព្រហ្មទណ្ឌដើម្បីបង្រ្កាបការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ ដូចជាករណីបរិហារកេរ្តិ៍ជាដើម។ ច្បាប់បរិហារកេរ្តិ៍តាមបែបរដ្ឋប្បវេណី អាចចែងពីទោសទណ្ឌ ដូចជាការសុំទោស ការកែតម្រូវ និងសំណងខូចខាតជូនជនរងគ្រោះដោយសារការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ។

បើគិតចេញពីទស្សនៈគោលនយោបាយ ការកំណត់ថាការផ្សព្វផ្សាយព័ត៌មាន "ក្លែងក្លាយ" ជាបទឧក្រិដ្ឋ ដូចនៅក្នុងមាត្រា ៤៩ នៃសេចក្តីព្រាងច្បាប់ នឹង៖ (ក) បំបាក់ទឹកចិត្តសារព័ត៌មានឯករាជ្យជាពិសេស សារព័ត៌មានតូចតាច និងរបាយការណ៍ដែលមានសារៈសំខាន់សម្រាប់គោលនយោបាយរដ្ឋាភិបាល (ខ) បង្កើតជាឥទ្ធិពលគួរឱ្យខ្លាចរអាដល់ការជជែកវែកញែកជាសាធារណៈ (គ) ធ្វើឱ្យគណនេយ្យភាពរដ្ឋាភិបាល និងសាធារណៈចុះអន់ខ្សោយ ដោយសារតែការបញ្ចេញមតិរិះគន់ ត្រូវបានកំណត់ថាជាបទឧក្រិដ្ឋ (ឃ) ធ្វើឱ្យព័ត៌មានស្តីពីតម្រូវការសហគមន៍មានតិចជាងមុន សម្រាប់ផ្តល់ឱ្យអ្នកធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាល និងឈានដល់ការបង្អាក់លទ្ធភាពរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហានានា និង(ង)ធ្វើឱ្យលទ្ធិប្រជាធិបតេយ្យចុះអន់ខ្សោយ។ បើនិយាយបែបចំអកឡកឡឺយ ច្បាប់ដែលព្យាយាមហាមឃាត់ការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ អាចនឹងបង្រ្កាបដល់ការផ្តល់ "ព័ត៌មានពិត" រួមទាំងការបញ្ចេញមតិមិនប្រកាន់បក្សពួក ការវិភាគជាសត្យានុម័ត ជាពិសេសការវិភាគដែលជេញដោលនឹងគោលនយោបាយរដ្ឋាភិបាល ឬជំហររបស់រដ្ឋាភិបាល។

**អនុសាសន៍៖** គួរលុបចោលមាត្រា ៤៩។

## សិទ្ធិអំណាចទូលំទូលាយពេកក្នុងការឆែកឆេរ និងរឹបអូស

**បញ្ហា៖** យោងតាមមាត្រា ១៤(១) នៃសេចក្តីព្រាងច្បាប់ មន្ត្រីនគរបាលយុត្តិធម៌អាចស្នើទៅតុលាការឱ្យចេញដីកាឆែកឆេរ ឬភ្ជាប់ប្រព័ន្ធកុំព្យូទ័រ ឬចូលទៅកាន់ទិន្នន័យនៅក្នុងប្រព័ន្ធកុំព្យូទ័រ

ដោយមិនចាំបាច់បំពេញតាមតម្រូវការឱ្យជឿជាក់ថាប្រព័ន្ធកុំព្យូទ័រ ឬទិន្នន័យនោះមានផ្ទុកភស្តុតាងពីបទឧក្រិដ្ឋនោះទេ។[22]

**ការវិភាគ៖** បញ្ញត្តិនេះអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌រឹបអូសយកកុំព្យូទ័រ ឬប្រព័ន្ធស្តុកទិន្នន័យ ធ្វើការថតចម្លង និងរក្សាទុកច្បាប់ថតចម្លងនៃទិន្នន័យកុំព្យូទ័របាន និងធ្វើឱ្យមិនអាចចូលទៅយកទិន្នន័យបាន ឬលុបចោលទិន្នន័យចេញពីប្រព័ន្ធកុំព្យូទ័របាន។ សិទ្ធិអំណាចទាំងនេះ នឹងរំខានដល់ប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល ធុរកិច្ចឯកជន មហាវិទ្យាល័យ អង្គភាពផ្សេងទៀត និងផ្តល់សិទ្ធិដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការចូលទៅយកព័ត៌មានរសើបអំពីសកម្មភាព បុគ្គលិក សមាជិក ម្ចាស់ជំនួយ អង្គការដៃគូ ឬវិនិយោគិនរបស់អង្គភាពទាំងនោះដោយគ្មានកម្រិតអប្បបរមានៃភាពជឿជាក់ថាស្ថាប័ននោះ ឬបុគ្គលិកពាក់ព័ន្ធ មានជាប់ទាក់ទិននឹងសកម្មភាពឧក្រិដ្ឋឬអត់។

ដើម្បីការពារនឹងការបំពានអំណាចតាមដានបុគ្គល និងអង្គការនានា រួមទាំងអង្គការសង្គមស៊ីវិល សេចក្តីព្រាងច្បាប់នេះ ត្រូវកំណត់ពីស្តង់ដារភស្តុតាង ដូចជា "ភវនីយហេតុ" ដែលអាចឱ្យអាជ្ញាធរមានសមត្ថកិច្ចភ្ជាប់ប្រព័ន្ធកុំព្យូទ័រ ឬចូលទៅកាន់ទិន្នន័យកុំព្យូទ័របាន។ សេចក្តីព្រាងច្បាប់ បានតម្រូវរួចទៅហើយនៅក្នុងបញ្ញត្តិមួយចំនួននៃសេចក្តីព្រាងច្បាប់នេះ ដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវឈរលើ "ហេតុផលសមរម្យក្នុងការជឿជាក់" ថាការភ្ជាប់ប្រព័ន្ធកុំព្យូទ័រ ឬចូលទៅកាន់ទិន្នន័យ គឺដើម្បីស្វែងរកភស្តុតាងពីបទឧក្រិដ្ឋ ឬពាក់ព័ន្ធនឹងបុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេតពីបទឧក្រិដ្ឋ។[23] ក៏ប៉ុន្តែ "ហេតុផលសមរម្យ" គឺជាស្តង់ដារទាបមួយក្នុងការបំពេញ និងចាត់ជាការអនុម័តតាមហេតុការណ៍ពិត *(de facto)* នៃសំណើអនុវត្តច្បាប់។[24] ការអនុម័តយកស្តង់ដារ "ភវនីយហេតុ" អាចនឹងផ្តល់ជាការការការពារឱ្យបានប្រសើរជាងនេះទៅនឹងការតាមដានដែលមិនត្រឹមត្រូវ។ បណ្តា

---

[22] មាត្រា ១៤(១) នៃសេចក្តីព្រាងច្បាប់ ចែងថា "ដើម្បីស្វែងរក ឬប្រមូលភស្តុតាងចាំបាច់សម្រាប់ការស៊ើបអង្កេតពីបទឧក្រិដ្ឋ ដែលប្រព័ន្ធកុំព្យូទ័រ ឬឧបករណ៍ស្តុកទិន្នន័យកុំព្យូទ័រអាចមានផ្ទុកភស្តុតាងពីបទឧក្រិដ្ឋ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្នើសុំទៅតុលាការឱ្យចេញ៖

- ដីកាឆែកឆេរ ឬភ្ជាប់ប្រព័ន្ធកុំព្យូទ័រទាំងមូល ឬដោយផ្នែក និងទិន្នន័យកុំព្យូទ័រដែលមានស្តុកក្នុងប្រព័ន្ធកុំព្យូទ័រនោះ
- ដីកាឆែកឆេរ ឬចូលប្រើឧបករណ៍ស្តុកកុំព្យូទ័រ ឬទិន្នន័យ ដែលអាចមានស្តុកទិន្នន័យកុំព្យូទ័រ និង
- ប្រើប្រាស់សមត្ថភាពបច្ចេកទេសដែលមានស្រាប់ ដោយមានជំនួយខាងលើ តាមការចាំបាច់។"

[23] ជាឧទាហរណ៍ សូមមើលមាត្រា ១២(១), ១៣(១), ១៥(១) និង១៦(១) នៃសេចក្តីព្រាងច្បាប់

[24] សូមមើលកថាខណ្ឌទី៥៦ ផ្នែក "ក" ("អន្តរទំនាក់ទំនងរវាងសិទ្ធិឯកជនភាព និងសេរីភាពបញ្ចេញមតិ និងយោបល់") នៃ *"របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសេរីភាពបញ្ចេញមតិ និងយោបល់"* ដោយ Frank La Rue ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40 (ឆ្នាំ២០១៣)។

ប្រទេសដូចជាសហរដ្ឋអាមេរិក បានអនុម័តប្រើស្តង់ដារភវនីយហេតុសម្រាប់ការតាមដានតាមបែបអេឡិចត្រូនិច។[25]

មាត្រា ១៤(១) នៃសេចក្តីព្រាងច្បាប់ ក៏គួរតែកែសម្រួល ដើម្បីជានាការការពារតាមនីតិវិធីសម្រាប់ការឆែកឆេរ និងរឹបអូស ស្របតាមច្បាប់អន្តរជាតិ។ ការការពារទាំងនេះ រួមមានលក្ខខណ្ឌតម្រូវឱ្យទទួលបានដីកាតុលាការ ដោយផ្អែកលើភវនីយហេតុនៃការប្រព្រឹត្តល្មើសនឹងច្បាប់ មុនពេលធ្វើការឆែកឆេរ និងរឹបអូស ព្រមទាំងមានផ្តល់ជាព័ត៌មានលម្អិតពីវត្ថុតាងដែលស្ថិតក្រោមការស៊ើបអង្កេតតាមដានដោយផ្ទាល់ពីបទឧក្រិដ្ឋ ការកម្រិតពីរយៈពេលនៃការអនុវត្តដីកា និងលក្ខខណ្ឌតម្រូវឱ្យបំផ្លាញវត្ថុតាងដែលរឹបអូសបាន បន្ទាប់ពីបិទបញ្ចប់ការស៊ើបអង្កេត។[26, 27]

**អនុសាសន៍៖** នៅក្នុងមាត្រា ១៤(១) នៃសេចក្តីព្រាងច្បាប់ ការតម្រូវឱ្យមន្ត្រីនគរបាលយុត្តិធម៌មាន "ភវនីយហេតុ" ក្នុងការជឿជាក់ថាប្រព័ន្ធកុំព្យូទ័រ ឬឧបករណ៍ស្តុកទិន្នន័យកុំព្យូទ័រមានផ្ទុកភស្តុតាងពីបទឧក្រិដ្ឋ មុនពេលស្នើសុំទៅតុលាការឱ្យចេញដីកាឆែកឆេរ និងរឹបអូស។ ដីកាតុលាការត្រូវតែផ្អែកលើការសង្ស័យសមហេតុផលអំពីការប្រព្រឹត្តល្មើសនឹងច្បាប់ ដោយពន្យល់បកស្រាយឱ្យបានច្បាស់អំពីវត្ថុតាងដែលស្ថិតក្រោមការតាមដាន ត្រូវតែពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបទឧក្រិដ្ឋដែលកំពុងតែស្ថិតក្រោមការស៊ើបអង្កេត ការកម្រិតពីរយៈពេលតាមដាន និងតម្រូវការឱ្យបំផ្លាញវត្ថុតាងដែលរឹបអូសបាននោះ បន្ទាប់ពីធ្វើការសន្និដ្ឋានពីការស៊ើបអង្កេតរួច។ គួរពិចារណាបង្កើតជាស្ថាប័ន

[25] ឯកសាររបស់ស្ថាប័នព័ត៌មានច្បាប់នៃសាលាច្បាប់ Cornell ស្តីពី "ការតាមដានបែបអេឡិចត្រូនិច" ដែលអាចរកមើលបានតាមរយៈ: https://www.law.cornell.edu/wex/electronic_surveillance#:~:text=To%20obtain%20a%20warrant%2C%20the,the%20surveillance%2C%20among%20other%20requirements.

[26] សូមមើលកថាខណ្ឌទី៨១ ផ្នែក "ក" ("អន្តរទំនាក់ទំនងរវាងសិទ្ធិឯកជនភាព និងសេរីភាពបញ្ចេញមតិ និងយោបល់") នៃ *"របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសេរីភាពបញ្ចេញមតិ និងយោបល់"* ដោយ Frank La Rue ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40 (ឆ្នាំ២០១៣)។ សូមមើលកថាខណ្ឌទី ៣៧-៣៨ នៃឯកសារ *"សិទ្ធិឯកជនភាពនៅក្នុងយុគសម័យឌីជីថល"* របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/27/37 (ឆ្នាំ២០១៤) ដែលអាចរកមើលបានតាមរយៈ: https://www.ohchr.org/sites/default/files/HRBodies/HRC/RegularSessions/Session27/Documents/A.HRC.27.37_en.pdf និងកថាខណ្ឌទី ៥២ នៃ *"របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសេរីភាពបញ្ចេញមតិ និងយោបល់"* ដោយលោក David Kaye ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិលេខ A/HRC/41/35 (ឆ្នាំ២០១៩)

[27] ដើម្បីការពារសិទ្ធិឯកជនភាពឱ្យបានប្រសើរជាងនេះ ទន្ទឹមនឹងនៅតែអនុញ្ញាតឱ្យមានការតាមដានការអនុវត្តច្បាប់ រដ្ឋាភិបាលបានចាប់ផ្តើមអនុម័តគំរូតាមដានពិនិត្យបែបចំរុះមួយ តាមផ្លូវតុលាការ សភា និងសាធារណជន។ ជាឧទាហរណ៍ ទីក្រុង Oakland ក្នុងរដ្ឋកាលីហ្វរញ៉ា នៃសហរដ្ឋអាមេរិក បានដាក់ដំណើរការអនុម័តការទិញបច្ចេកវិទ្យាតាមដាន ដែលធ្វើឡើងដោយអាជ្ញាធរពាក់ព័ន្ធ ចេញជាសេចក្តីជូនដំណឹងសាធារណៈអំពីការទិញបច្ចេកវិទ្យាតាមដាន និងចេញជារបាយការណ៍សាធារណៈជាប្រចាំអំពីការអនុម័តទាំងនោះ ការទិញ និងការប្រើប្រាស់បច្ចេកវិទ្យាតាមដាន។

ឯករាជ្យមួយសម្រាប់អនុម័ត និងធ្វើការរាយការណ៍អំពីសកម្មភាពតាមដានរបស់រដ្ឋាភិបាលទាំងអស់។

## ការពន្យារពេលដែលមិនកំណត់រយៈពេល នៃការចូលទៅកាន់ទិន្នន័យចរាចរណ៍ និងទិន្នន័យខ្លឹមសារ

**បញ្ហា៖** មាត្រា ១៥(២) និង១៦(២) នៃសេចក្តីព្រាងច្បាប់ ហាក់ដូចជាអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំពន្យារពេលដែលមិនកំណត់រយៈពេលសម្រាប់ប្រមូលទិន្នន័យចរាចរណ៍[28] (ដូចជា ទិន្នន័យទាក់ទងនឹងការផ្ញើ ពេលវេលា និងរយៈពេលជាដើម) និងការចាប់យកទិន្នន័យខ្លឹមសារ។[29] ការស្នើសុំពន្យារពេលនេះ អាចនាំឱ្យមានការតាមដានរយៈពេលយូរទៅលើសង្គមស៊ីវិល និងសាធារណជន ដែលដាក់កម្រិតដល់សិទ្ធិឯកជនភាព និងអាចប៉ះពាល់ដល់សេរីភាពពលរដ្ឋ។

**ការវិភាគ៖** ស្របតាមច្បាប់អន្តរជាតិ ច្បាប់ដែលអនុញ្ញាតឱ្យមានការតាមដានទិន្នន័យអេឡិចត្រូនិច ឬការប្រាស្រ័យទាក់ទងរបស់ប្រជាជន ត្រូវតែមានរួមបញ្ចូលការការពារពីប្រភេទ វិសាលភាព និងរយៈពេលនៃការដាក់វិធានការតាមដាន មូលហេតុតម្រូវឱ្យមានការចេញដីកា អាជ្ញាធរមានសមត្ថកិច្ចដែលទទួលបន្ទុកផ្តល់សិទ្ធិ អនុវត្ត និងពិនិត្យតាមដានវិធានការនោះ និងប្រភេទនៃសំណងដែលផ្តល់ដោយច្បាប់ជាតិ។[30] ការការពារទាំងនេះ រួមបញ្ចូលការដាក់កម្រិតពីពេលវេលាតឹងរឹងសម្រាប់វិធានការតាមដាន។ អតិក្រមរបស់ប្រទេសអាល្លឺម៉ង់ មានលក្ខណៈជាការណែនាំ គឺ៖ តុលាការអាចចេញដីកាឱ្យតាមដាន/ចាប់យកទិន្នន័យចរាចរណ៍ ឬខ្លឹមសារបានសម្រាប់រយៈពេលហួតដល់

---

[28] មាត្រា ១៥(២) នៃសេចក្តីព្រាងច្បាប់ អនុញ្ញាតឱ្យតុលាការផ្តល់ការពន្យារពេល "សម្រាប់រយៈពេលកំណត់មួយបន្ថែម" ទៅលើដីកាដែលបានចេញពីពេលមុន ទៅឱ្យអ្នកផ្តល់សេវាក្នុងការប្រមូល កត់ត្រា និងផ្តល់ទិន្នន័យចរាចរណ៍អំពីការប្រាស្រ័យទាក់ទងជាក់លាក់ជូនមន្ត្រីនគរបាលយុត្តិធម៌ ដែលមានហេតុផលសមរម្យក្នុងការជឿជាក់ថាត្រូវមានទិន្នន័យចរាចរណ៍សម្រាប់ការស៊ើបអង្កេតពីបទឧក្រិដ្ឋ។

[29] មាត្រា ១៦(២) នៃសេចក្តីព្រាងច្បាប់ អនុញ្ញាតឱ្យតុលាការផ្តល់ការពន្យារពេល "សម្រាប់រយៈពេលកំណត់មួយបន្ថែម" ទៅលើដីកាដែលបានចេញពីពេលមុន ទៅឱ្យមន្ត្រីនគរបាលយុត្តិធម៌ ឬអ្នកផ្តល់សេវាក្នុងការប្រមូល ឬកត់ត្រាទិន្នន័យចរាចរណ៍ ដែលមានហេតុផលសមរម្យក្នុងការជឿជាក់ថាទិន្នន័យចរាចរណ៍នោះមានពាក់ព័ន្ធនឹងការស៊ើបអង្កេតពីបទឧក្រិដ្ឋ។

[30] សូមមើល កថាខណ្ឌទី ៨១ ផ្នែក "ក" ("អន្តរទំនាក់ទំនងរវាងសិទ្ធិឯកជនភាព និងសេរីភាពបញ្ចេញមតិ និងយោបល់") នៃ *"របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសេរីភាពបញ្ចេញមតិ និងយោបល់"* ដោយ Frank La Rue ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40 (ឆ្នាំ២០១៣)។ សូមមើល កថាខណ្ឌទី ៥០ នៃ *"របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសេរីភាពបញ្ចេញមតិ និងយោបល់"* ដោយលោក David Kaye ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិលេខ A/HRC/41/35 (ឆ្នាំ២០១៩)

១៨០ ថ្ងៃ ហើយបន្ទាប់មកអាចអនុញ្ញាតឱ្យពន្យារពេលបានរហូតដល់ ១៨០ ថ្ងៃទៀត ប៉ុន្តែលុះត្រាតែមានលក្ខខណ្ឌសម្រាប់ស្នើសុំដីកានៅតែយកមកអនុវត្តដដែល។

តាមរយៈការអនុញ្ញាតឱ្យតុលាការបន្តរយៈពេលនៃដីកាតាមដាន "សម្រាប់រយៈពេលជាក់លាក់បន្ថែម" មាត្រា ១៥(២) និង១៦(២) មិនបានកំណត់ពីកាលបរិច្ឆេទបញ្ចប់ជាក់ច្បាស់ណាមួយសម្រាប់រយៈពេលបន្តតាមដាននោះទេ។ តុលាការអាចបកស្រាយថាការផ្តល់រយៈពេលបន្ថែមដល់ដីកាតាមដាននេះបានជាច្រើនខែ ច្រើនឆ្នាំ ឬឥតមានរយៈពេលកំណត់ក៏បាន។ ដោយគ្មានការដាក់កម្រិតអំពីរយៈពេល និងលក្ខខណ្ឌតម្រូវសម្រាប់ការពន្យារពេល មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំចូលទៅកាន់ទិន្នន័យចរាចរណ៍ និងទិន្នន័យខ្លឹមសារសម្រាប់ចិរវេលាមិនកំណត់បាន និងដោយគ្មានការដាក់កម្រិតច្បាស់លាស់អំពីរបៀបប្រើប្រាស់ទិន្នន័យផងដែរ។ សិទ្ធិអំណាចទាំងនេះដាក់កម្រិតទៅលើសិទ្ធិឯកជនភាព។ មន្ត្រីនគរបាលយុត្តិធម៌អាចសំអាងដីកាតុលាការក្នុងការបន្តការតាមដានអង្គការសង្គមស៊ីវិល បុគ្គល ឬក្រុមហ៊ុនឯកជន ទោះបីជានីតិវិធីស៊ើបអង្កេតបានបិទបញ្ចប់ហើយក្តី។ មន្ត្រីនគរបាលយុត្តិធម៌ អាចជ្រៀតជ្រែកសកម្មភាពរបស់អង្គការសង្គមស៊ីវិល ពលរដ្ឋធម្មតា ឬក្រុមហ៊ុនឯកជន ដោយប្រើប្រាស់ព័ត៌មានដែលទទួលបានពីការតាមដាន ក្នុងគោលបំណងបង្អាក់សកម្មភាពតវ៉ាតាមផែនការ ឬសកម្មភាពស្របច្បាប់ផ្សេងៗបាន។

មាត្រា ១៥(១) និងមាត្រា ១៦(១) នៃសេចក្តីព្រាងច្បាប់ ដាក់កម្រិតរយៈពេលតាមដានក្នុងដីកាតុលាការ ត្រឹមរយៈពេល ១៤ ថ្ងៃ និងតម្រូវឱ្យមន្ត្រីនគរបាលយុត្តិធម៌ចង្អុលបង្ហាញមូលហេតុសមរម្យក្នុងការជឿជាក់ថាទិន្នន័យចរាចរណ៍ និងទិន្នន័យខ្លឹមសារ មានពាក់ព័ន្ធនឹងការស៊ើបអង្កេតពីបទឧក្រិដ្ឋ។ ការកែសម្រួលមាត្រា ១៥(២) និងមាត្រា ១៦(២) នៃសេចក្តីព្រាងច្បាប់ ឱ្យប្រើរយៈពេលមានកំណត់សម្រាប់ការពន្យារពេល (ដូចជារយៈពេល ១៨០ ថ្ងៃ) និងការបញ្ជាក់ច្បាស់ពីមូលហេតុស្នើសុំការពន្យារពេល អាចជួយការពារមិនឱ្យមានការបំពានអំណាចក្នុងការតាមដានអង្គការសង្គមស៊ីវិល និងបុគ្គល លើសពីការស៊ើបអង្កេតពីបទឧក្រិដ្ឋ។

**អនុសាសន៍៖** គួរកែសម្រួលមាត្រា ១៥(២) និង ១៦(២) នៃសេចក្តីព្រាងច្បាប់ ដើម្បីកម្រិតពីរយៈពេលបន្តនៃដីកាតុលាការត្រឹមចំនួនអតិបរមា ១៨០ ថ្ងៃ និងតម្រូវឱ្យមន្ត្រីនគរបាលយុត្តិធម៌ចង្អុលបង្ហាញពីមូលហេតុសមហេតុផលក្នុងការជឿជាក់ថាការចូលទៅកាន់ទិន្នន័យចរាចរណ៍ និងទិន្នន័យខ្លឹមសារជាបន្ត អាចពាក់ព័ន្ធនឹងការស៊ើបអង្កេតពីបទឧក្រិដ្ឋ។

## សិទ្ធិអំណាចទូលំទូលាយពេកក្នុងការចែកចាយទិន្នន័យ

**បញ្ហា៖** មាត្រា ២៦ នៃសេចក្តីព្រាងច្បាប់ ចែងថាមន្ត្រីមានសមត្ថកិច្ចអាចចែករំលែកទិន្នន័យអំពីបុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេតបាន ប្រសិនបើមន្ត្រីមាន "សិទ្ធិ ការដោះសារ ឬយុត្តិកម្មស្របច្បាប់"។[31]

**ការវិភាគ៖** ការជ្រៀតជ្រែកទៅលើសិទ្ធិឯកជនភាព ដូចជាតាមរយៈការតាមដាន ត្រូវតែទទួលបានការប្រគល់សិទ្ធិតាមច្បាប់ ដែលធានាថាការប្រមូលទិន្នន័យត្រូវបានតម្រឹមត្រឹមគោលបំណងស្របច្បាប់ជាក់លាក់ប៉ុណ្ណោះ និងមានភាពច្បាស់លាស់គ្រប់គ្រាន់ ព្រមទាំងបញ្ជាក់លម្អិតពីលក្ខខណ្ឌជាក់ច្បាស់ដែលអនុញ្ញាតឱ្យមានការជ្រៀតជ្រែកនោះ។[32] ជាឧទាហរណ៍ នៅក្នុងសេចក្តីព្រាងច្បាប់ អាជ្ញាធរត្រូវមានកាតព្វកិច្ចការពារទិន្នន័យដែលចាប់យក និងដាក់កម្រិតពីការចែករំលែក ឬប្រើប្រាស់ទិន្នន័យនោះ សម្រាប់ជួយសម្រួលដល់នីតិវិធីស៊ើបអង្កេត ឬការចោទប្រកាន់ពីបទឧក្រិដ្ឋណាមួយ។

ទោះបីជាមាត្រា ២៦ នៃសេចក្តីព្រាងច្បាប់ បានកំណត់សកម្មភាពរបស់មន្ត្រីមានសមត្ថកិច្ចក្នុងការចែករំលែកទិន្នន័យបុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេតថាជាបទល្មើសក្តី ប៉ុន្តែមន្ត្រីត្រូវមានសិទ្ធិ ការដោះសារ ឬយុត្តិកម្មស្របច្បាប់ ដែលជាហេតុធ្វើឱ្យមាត្រានេះមានលក្ខណៈទូលាយក្នុងការអនុលោមតាមច្បាប់អន្តរជាតិណាស់។

បញ្ញត្តិនេះ មិនបំពេញតាមគោលការណ៍នីត្យានុកូលភាព ដោយហេតុថាវាពិបាកលៃលកបានសម្រាប់មន្ត្រីមានសមត្ថកិច្ចក្នុងការយល់ដឹងថា នៅពេលណាដែល "ការដោះសារ ឬយុត្តិកម្ម" នឹងអនុញ្ញាតឱ្យចែករំលែកទិន្នន័យបុគ្គល។ វាក្យស័ព្ទទាំងនេះ មានលក្ខណៈស្រពិចស្រពិលក្នុងការផ្តល់សិទ្ធិឱ្យមន្ត្រីមានសមត្ថកិច្ចកំណត់ថាវាជាការចាំបាច់ក្នុងការចែករំលែកទិន្នន័យបុគ្គល។ សិទ្ធិអំណាចទាំងនេះ បង្កើតជាក្តីបារម្ភរឿងឯកជនភាព៖ មន្ត្រីមានសមត្ថកិច្ចអាចចែករំលែកព័ត៌មានសើបអំពីបុគ្គលិក សមាជិក អ្នកទទួលផល ឬអង្គការដៃគូ របស់អង្គការសង្គមស៊ីវិល នៅពេលដែលអង្គការសង្គមស៊ីវិលស្ថិតក្រោមការស៊ើបអង្កេត ដោយសារតែមន្ត្រីមានសមត្ថកិច្ចជឿជាក់ថាសាធារណជន មិនគួរទុកចិត្តអង្គការសង្គមស៊ីវិល និងបុគ្គលិកពាក់ព័ន្ធនោះទេ។ "ការដោះសារ ឬ

---

[31] មាត្រា ២៦ នៃសេចក្តីព្រាងច្បាប់ ចែងថា "មន្ត្រីមានសមត្ថកិច្ចដែលមានចេតនាចែកចាយទិន្នន័យកុំព្យូទ័រ ទិន្នន័យចរាចរណ៍ ឬទិន្នន័យផ្សេងរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេត និងដោយគ្មានសិទ្ធិ ការដោះសារ ឬយុត្តិកម្មស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ.....និងពិន័យជាប្រាក់...។"

[32] សូមមើល កថាខណ្ឌទី ២៨ នៃឯកសារ *"សិទ្ធិឯកជនភាពនៅក្នុងយុគសម័យឌីជីថល"* របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/27/37 (ឆ្នាំ២០១៤) ដែលអាចរកមើលបានតាមរយៈ https://www.ohchr.org/sites/default/files/HRBodies/HRC/RegularSessions/Session27/Documents/A.HRC.27.37_en.pdf

យុត្តិកម្ម” ប្រភេទនេះ អាចធ្វើឱ្យសង្គមស៊ីវិល និងតួអង្គផ្សេងទៀតប្រឈមមុខនឹងការសងសឹកពីសំណាក់អាជ្ញាធរ។

**អនុសាសន៍៖** នៅក្នុងមាត្រា ២៦ នៃសេចក្តីព្រាងច្បាប់ គួរលុបចោលពាក្យថា "ការដោះសារ ឬយុត្តិកម្ម” ថាជាមូលដ្ឋានសម្រាប់មន្ត្រីមានសមត្ថកិច្ចក្នុងការចែករំលែកទិន្នន័យរបស់បុគ្គល។

## ការការពារអ្នកផ្តល់ព័ត៌មាន (whistleblowers)

**បញ្ហា៖** មាត្រា ៣៤ នៃសេចក្តីព្រាងច្បាប់ អនុញ្ញាតឱ្យបុគ្គលដែលភ្ជាប់ប្រព័ន្ធកុំព្យូទ័រ[33] និងមាត្រា ៣៦ នៃសេចក្តីព្រាងច្បាប់ អនុញ្ញាតឱ្យបុគ្គលចូលទៅចាប់យកទិន្នន័យ[34] ប្រសិនបើបុគ្គល "មានសិទ្ធិ ការដោះសារ ឬយុត្តិកម្មស្របច្បាប់។” មាត្រាទាំងពីរនេះ អាចសំដៅការពារអ្នកស្រាវជ្រាវ ឬជំនាញការផ្នែកសន្តិសុខ ក្នុងការធ្វើតេស្តប្រព័ន្ធកុំព្យូទ័ររបស់អង្គការសាធារណៈ និងឯកជន។ ទោះជាយ៉ាងនេះក្តី បញ្ញត្តិទាំងនេះ គួរតែត្រូវបានពង្រីកវិសាលភាពការពារឱ្យបានច្បាស់លាស់ដល់អ្នកផ្តល់ព័ត៌មានផងដែរ។

បន្ថែមពីលើនេះ មាត្រា ៣៥ កំណត់ថាការភ្ជាប់ប្រព័ន្ធកុំព្យូទ័រលើសពីប៉ារ៉ាម៉ែត្រអនុញ្ញាតឱ្យប្រព័ន្ធជាបទឧក្រិដ្ឋ[35] ដែលអាចត្រូវបានបកស្រាយថាហាមឃាត់អ្នកផ្តល់ព័ត៌មានដែលភ្ជាប់ប្រព័ន្ធកុំព្យូទ័រដោយគ្មានការអនុញ្ញាត។

**ការវិភាគ៖** សេរីភាពបញ្ចេញមតិ ការពារអ្នកផ្តល់ព័ត៌មាន ដែលគិតគូរពីសិទ្ធិរបស់សាធារណជនក្នុងការទទួលបានព័ត៌មានដែលបម្រើដល់ផលប្រយោជន៍សាធារណៈ។[36] ច្បាប់ គួរតែការពារអ្នកផ្តល់ព័ត៌មាន ដែលជាបុគ្គលបញ្ចេញព័ត៌មានដែលអាចជឿជាក់សមហេតុផលថាបង្កជាការគំរាមកំហែង ឬអន្តរាយដល់ផលប្រយោជន៍សាធារណៈជាក់លាក់ ដូចជាការបំពាននឹងច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ការបំពានអំណាច កាកសំណល់ ការឆបោក ឬការប៉ះពាល់ដល់បរិស្ថាន សុខមាលភាព

---

[33] មាត្រា ៣៤ នៃសេចក្តីព្រាងច្បាប់ ចែងថា "បុគ្គលណាដែលមានចេតនាភ្ជាប់ប្រព័ន្ធកុំព្យូទ័រទាំងស្រុង ឬដោយផ្នែក ដោយគ្មានសិទ្ធិ ការដោះសារ ឬយុត្តិកម្មស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ.....និងពិន័យជាប្រាក់...។”

[34] មាត្រា ៣៦ នៃសេចក្តីព្រាងច្បាប់ ចែងថា "បុគ្គលណាដែលមានចេតនាចូលទៅចាប់យកទិន្នន័យដែលផ្ទេរទៅ ផ្ទេរមកពី ឬនៅក្នុងប្រព័ន្ធកុំព្យូទ័រ ដោយប្រើមធ្យោបាយណាមួយក៏ដោយ ដោយគ្មានសិទ្ធិ ការដោះសារ ឬយុត្តិកម្មស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ.....និងពិន័យជាប្រាក់...។”

[35] មាត្រា ៣៥ នៃសេចក្តីព្រាងច្បាប់ ចែងថា "បុគ្គលណាដែលមានសិទ្ធិភ្ជាប់ប្រព័ន្ធកុំព្យូទ័រទាំងស្រុង ឬដោយផ្នែក ប៉ុន្តែបានយក ថតចម្លង ប្រើប្រាស់ និង/ឬ ផ្ទេរទិន្នន័យកុំព្យូទ័រ ឬព័ត៌មានរបស់ម្ចាស់ទិន្នន័យ ដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ.....និងពិន័យជាប្រាក់...។”

[36] កថាខណ្ឌទី ៥ នៃឯកសាររបស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពី *ការលើកស្ទួយ និងការការពារសេរីភាពបញ្ចេញមតិ និងយោបល់៖* កំណត់សម្គាល់របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ លេខ A/70/361 (ឆ្នាំ២០១៥)

សាធារណៈ ឬសុវត្ថិភាពសាធារណៈ។[37] ច្បាប់ពាក់ព័ន្ធនឹងអ្នកផ្តល់ព័ត៌មាន ត្រូវការពារអ្នកផ្តល់ព័ត៌មាន ទោះបីជាពួកគាត់ផ្តល់ដំណឹងក្រៅពីទំនាក់ទំនងការងារក្តី។[38] បន្ថែមពីលើការការពារអ្នកជំនាញការផ្នែកសន្តិសុខ មាត្រា ៣៤ និង៣៦ នៃសេចក្តីព្រាងច្បាប់ ហាក់ដូចជាការពារអ្នកផ្តល់ព័ត៌មាន ដែលពួកគាត់អាចភ្ជាប់ប្រព័ន្ធកុំព្យូទ័រ ឬចាប់យកទិន្នន័យ ដើម្បីចែករំលែកព័ត៌មានដែលអាចបង្កអន្តរាយដល់ផលប្រយោជន៍សាធារណៈ ទោះបីជាពួកគាត់មិនមានសិទ្ធិស្របច្បាប់ឱ្យធ្វើបែបនោះក៏ដោយ។ បញ្ញត្តិទាំងនេះ គួរតែកែសម្រួលដើម្បីការពារឱ្យបានច្បាស់លាស់ដល់បុគ្គលដែលចូលទៅកាន់ ឬចាប់យកទិន្នន័យដែលអាចជឿទុកចិត្តដោយសមហេតុផលថាបង្កជាការគំរាមកំហែង ឬប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈជាក់ច្បាស់ណាមួយ។

ផ្ទុយទៅវិញ មាត្រា ៣៥ នៃសេចក្តីព្រាងច្បាប់ ហាក់ដូចជាហាមឃាត់អ្នកផ្តល់ព័ត៌មានមិនឱ្យភ្ជាប់ប្រព័ន្ធកុំព្យូទ័រដោយគ្មានការអនុញ្ញាត។ បញ្ញត្តិនេះ គួរតែកែសម្រួលដោយបន្ថែមលក្ខខណ្ឌលើកលែងសម្រាប់បុគ្គលដែលភ្ជាប់ប្រព័ន្ធកុំព្យូទ័រ ដោយគ្មានការអនុញ្ញាតដើម្បីចែករំលែកព័ត៌មានដែលអាចបង្កជាការគំរាមកំហែង ឬគ្រោះថ្នាក់ដល់ផលប្រយោជន៍សាធារណៈជាក់លាក់ និងមិនប៉ះពាល់ដល់ប្រព័ន្ធកុំព្យូទ័រ ឬទិន្នន័យនៅក្នុងនោះទេ។[39]

**អនុសាសន៍៖** គួរកែសម្រួលមាត្រា ៣៤ និង៣៦ នៃសេចក្តីព្រាងច្បាប់ ដើម្បីការពារឱ្យបានច្បាស់លាស់ចំពោះបុគ្គលដែលចូលទៅកាន់ ឬចាប់យកទិន្នន័យ ហើយមានភាពជឿជាក់ដោយសមហេតុផលថាអាចបង្កជាការគំរាមកំហែង ឬអន្តរាយដល់ផលប្រយោជន៍សាធារណៈជាក់លាក់ណាមួយនោះ។ គួរតែកែសម្រួលមាត្រា ៣៥ ដើម្បីបន្ថែមករណីលើកលែងចំពោះបុគ្គលដែលចូលទៅកាន់ ឬចាប់យកទិន្នន័យដែលបុគ្គលនោះជឿជាក់ដោយសមហេតុផលថាអាចបង្កជាការគំរាមកំហែង ឬអន្តរាយដល់ផលប្រយោជន៍សាធារណៈជាក់លាក់។

---

[37] កថាខណ្ឌទី ២៨ នៃឯកសាររបស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពី *ការលើកស្ទួយ និងការការពារសេរីភាពបញ្ចេញមតិ និងយោបល់៖* កំណត់សម្គាល់របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ លេខ A/70/361 (ឆ្នាំ២០១៥)

[38] កថាខណ្ឌទី ២៩ នៃឯកសាររបស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពី *ការលើកស្ទួយ និងការការពារសេរីភាពបញ្ចេញមតិ និងយោបល់៖* កំណត់សម្គាល់របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ លេខ A/70/361 (ឆ្នាំ២០១៥)

[39] សូមមើល ទំព័រទី ៤ នៃសេចក្តីប្រកាសរួម ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៤ របស់អ្នករាយការណ៍ពិសេសស្តីពីសេរីភាពបញ្ចេញមតិ និងយោបល់របស់អង្គការសហប្រជាជាតិ, អ្នកតំណាងសេរីភាពសារព័ត៌មាននៃអង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE), អ្នករាយការណ៍ពិសេសស្តីពីសេរីភាពបញ្ចេញមតិ នៃអង្គការបណ្តាប្រទេសនៅទ្វីបអាមេរិក (OAS)

## បញ្ហាផ្សេងទៀត

សេចក្តីព្រាងច្បាប់នេះ មានបញ្ហាមួយចំនួនផ្សេងទៀតដែលអាចប៉ះពាល់ដល់អ្នកប្រើប្រាស់អ៊ិនធើណិតនៅក្នុងប្រទេសកម្ពុជា៖

- មាត្រា ២ នៃសេចក្តីព្រាងច្បាប់ បង្កើតជាយុត្តាធិការសកល។ វិសាលភាពសេចក្តីព្រាងច្បាប់នេះ មានចែងនៅក្នុងមាត្រា ២ ដោយកំណត់ថា "អនុវត្តចំពោះបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដែលប្រព្រឹត្តនៅក្នុង ឬនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ ឬផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា។"[40] វិសាលភាពនេះ បង្កើតជាយុត្តាធិការសកលគ្របដណ្តប់គ្រប់អ្នកប្រើប្រាស់អ៊ិនធើណិតទាំងអស់ និងបង្កើតជាបញ្ហាចំបងៗចំនួនពីរ។ បញ្ហាទី ១ អ្នកប្រើប្រាស់អ៊ិនធើណិតជាច្រើន ជាពិសេសអ្នកប្រើប្រាស់នៅក្រៅប្រទេសកម្ពុជា មិនបានដឹងលឺពីសេចក្តីព្រាងច្បាប់ ឬការអនុវត្តច្បាប់នេះទេ។ បញ្ហាទី ២ ចំណាត់ប្រភេទនៃបទល្មើសដែលមានរៀបរាប់នៅក្នុងសេចក្តីព្រាងច្បាប់ ដែល "ប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ ឬផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា" មានលក្ខណៈទូលាយពេក ដែលស្ទើរតែរាល់ការពិភាក្សាទាំងអស់ទាក់ទងនឹងប្រទេសកម្ពុជា គឺសុទ្ធតែជាមតិអវិជ្ជមាន ឬជាការរិះគន់ ដែលអាចត្រូវបានចាត់ថ្នាក់ ថាជាបទល្មើសមួយដែរ។
- មាត្រា ២២ នៃសេចក្តីព្រាងច្បាប់ អនុញ្ញាតឱ្យបុគ្គលណាដែលបំពាននឹងសេចក្តីព្រាងច្បាប់បង់ "ប្រាក់ពិន័យអន្តរកាល" បាន រួចនឹង "រំលត់បទឧក្រិដ្ឋ"។ ការអនុញ្ញាតឱ្យបុគ្គលបំពានច្បាប់បង់ប្រាក់ពិន័យ ដើម្បី "រំលត់" បទល្មើសឧក្រិដ្ឋ ជាការរើសអើងដល់បុគ្គលដែលមិនអាចមានលទ្ធភាពបង់ប្រាក់ពិន័យអន្តរកាល ហើយត្រូវទទួលទោសដាក់ពន្ធនាគារសម្រាប់ជាការផ្តន្ទាទោសចំពោះការបំពាននឹងសេចក្តីព្រាងច្បាប់។ បទបញ្ញត្តិនេះ គួរតែលុបចេញ។
- មាត្រា ២៤ នៃសេចក្តីព្រាងច្បាប់ អនុញ្ញាតឱ្យមានការប្រកាសថានីតិបុគ្គលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬតំណាងអង្គការនោះ "ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ"។ បញ្ញត្តិនេះដកស្រង់ចេញពីមាត្រា ៤២ នៃក្រមព្រហ្មទណ្ឌយ៉ាងច្បាស់ក្រឡែត អំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល។ មាត្រា ២៤ នៃសេចក្តីព្រាងច្បាប់ ត្រូវឆ្លុះបញ្ចាំងពីភាសាដែលប្រើនៅក្នុងក្រមព្រហ្មទណ្ឌ ដែលអនុញ្ញាតឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌ "ចំពោះបទល្មើសដែលប្រព្រឹត្តក្នុងនាម

[40] មាត្រា ២ នៃសេចក្តីព្រាងច្បាប់

អង្គការ ដោយអង្គការ ឬតំណាងអង្គការនោះ"។ ខ្លឹមសារមាត្រានេះ ("ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ") មានអត្ថន័យទូលំទូលាយពេក និងអាចឱ្យនីតិបុគ្គលទទួលខុសត្រូវចំពោះសកម្មភាពដែលប្រព្រឹត្តដោយបុគ្គលដែលមិនមែនជាតំណាងរបស់អង្គការបានផងដែរ។

- មាត្រា ៣២ នៃសេចក្តីព្រាងច្បាប់ ហាមឃាត់ការផ្សព្វផ្សាយ និងការប្រមូលមូលនិធិ ដើម្បីទិញ លក់ ផ្លាស់ប្តូរ ឬប្រតិបត្តិការទូទាត់រូបិយប័ណ្ណគ្រីបតូ (Cryptocurrency) ដោយគ្មានការអនុញ្ញាត ឬអាជ្ញាប័ណ្ណពីអាជ្ញាធរមានសមត្ថកិច្ច។[41] រូបិយប័ណ្ណគ្រីបតូ គឺជាវិធីទូទាត់ប្រាក់ដែលគេទទួលស្គាល់ច្រើន និងប្រើប្រាស់នៅក្នុងធុរកិច្ច រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងរវាងបុគ្គល។ ក្រៅពីទោសព្រហ្មទណ្ឌសម្រាប់ការទូទាត់តាមរូបិយប័ណ្ណគ្រីបតូ រាជរដ្ឋាភិបាលកម្ពុជា គួរបង្កើតជាក្របខណ្ឌការងារគតិយុត្តិដែលអនុញ្ញាតឱ្យធ្វើការទូទាត់ប្រាក់ក្នុងលក្ខខណ្ឌច្បាស់លាស់ និងមានតម្លាភាព។
- និយមន័យនៃវាក្យស័ព្ទ "រូបអាសអាភាស" នៅក្នុងមាត្រា ៣ (១៦) នៃសេចក្តីព្រាងច្បាប់មានអត្ថន័យទូលាយ និងអាចបកស្រាយថាជាការហាមឃាត់ការងារបង្ហាញខាងសិល្បៈ។ ប្រទេសកម្ពុជា បានប្រើបញ្ញត្តិប្រហាក់ប្រហែលមួយនៅក្នុងក្រមព្រហ្មទណ្ឌ សំដៅដល់ស្ត្រីដែលស្លៀកពាក់ "លេចលើលេចក្រោម" [42] និងធ្លាប់បានស្នើឱ្យមានច្បាប់ហាមប្រាមការស្លៀកពាក់ "មិនសមរម្យ" ផងដែរ។[43] រដ្ឋាភិបាលអាចប្រើការហាមឃាត់រូបអាសអាភាសក្រោមសេចក្តីព្រាងច្បាប់នេះក្នុងន័យវាយប្រហារសកម្មជនជាស្ត្រីបាន។ ជាឧទាហរណ៍ រដ្ឋាភិបាលអាចលើកឡើងថាសកម្មជនជាស្ត្រី កំពុងធ្វើសកម្មភាពពាក់ព័ន្ធនឹងរូបអាសអាភាស ប្រសិនបើគាត់ស្លៀកសំលៀកបំពាក់បែបលេចលើលេចក្រោមបន្តិចនៅក្នុងយុទ្ធនាការតាមអនឡាញ។ ការបកស្រាយបែបនេះអាចកម្រិតសេរីភាពបញ្ចេញមតិ ជា

---

[41] មាត្រា ៣២ នៃសេចក្តីព្រាងច្បាប់ ចែងថា៖ រូបិយប័ណ្ណគ្រីបតូ៖ "បុគ្គលណាដែលផ្សព្វផ្សាយ និងប្រមូលមូលនិធិ ដើម្បីទិញ លក់ ផ្លាស់ប្តូរ ឬប្រតិបត្តិការទូទាត់រូបិយប័ណ្ណគ្រីបតូ (Cryptocurrency) តាមរយៈបច្ចេកវិទ្យាព័ត៌មាន ដោយគ្មានការអនុញ្ញាត ឬអាជ្ញាប័ណ្ណពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ.... និងពិន័យជាប្រាក់.... ។"

[42] ជាឧទាហរណ៍ សូមមើល អត្ថបទ "ប្រទេសកម្ពុជា៖ សម្រេចចោទប្រកាន់បែបរើសអើងទៅលើអ្នកលក់ទំនិញអនឡាញតាម បណ្តាញសង្គមហ្វេសប៊ុកម្នាក់ពីបទបង្ហោះរូបអាសអាភាស" របស់អង្គការ Amnesty International (ចុះផ្សាយថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០២០) ដែលអាចរកអានបានតាមរយៈ https://www.amnesty.org/en/latest/news/2020/02/cambodia-drop-discriminatory-pornography-charges-against-facebook-seller/.

[43] អត្ថបទសារព័ត៌មានរបស់វីអូអេ (VOA) "សកម្មជនជាស្ត្រី សម្តែងការមិនយល់ស្របនឹងបញ្ញត្តិស្តីពីភាពសមរម្យ នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ" (ចុះផ្សាយថ្ងៃទី៥ ខែសីហា ឆ្នាំ២០២០) ដែលអាចរកមើលបានតាមរយៈ https://www.voacambodia.com/a/5531328.html.

ពិសេសស្ត្រីដែលស្ថិតក្នុងក្រសែភ្នែកមហាជន ថាជារឿយៗត្រូវបានចាត់ជាកម្មវត្ថុនៃការរិះគន់អំពីភាពផ្លូវភេទរបស់ពួកគាត់។

លើសពីនេះ ទោសទណ្ឌចំពោះរូបអាសអាភាសនៅក្នុងសេចក្តីព្រាងច្បាប់ គួរមានសង្គតភាពនឹងទោសទណ្ឌចំពោះបទឧក្រិដ្ឋប្រហាក់ប្រហែលដែលអាចប្រៀបធៀបបានក្រោមច្បាប់ដែលមានស្រាប់។ មាត្រា ២៤៩ នៃក្រមព្រហ្មទណ្ឌ ស្តីពីបទបង្ហាញកេរភេទ សំដៅផ្តន្ទាទោសជនល្មើស ដាក់ពន្ធនាគារចាប់ពី ៦ ថ្ងៃ ទៅ ៣ ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ៥០០ ០០០ (ប្រាំសែន) រៀល។ មាត្រា ៣៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្តន្ទាទោសដាក់ពន្ធនាគារជនណាដែលចែកចាយរូបភាព និងសម្ភារៈអាសអាភាស ពី ៧ ថ្ងៃ ទៅ ១ ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ២០០ ០០០ (ពីរសែន) រៀល; ផ្តន្ទាទោសដាក់ពន្ធនាគារជនណាដែលផលិតរូបភាព និងសម្ភារៈអាសអាភាស ពី ១ ខែ ទៅ ១ ឆ្នាំ និងពិន័យជាប្រាក់ពី ២០០ ០០០ (ពីរសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល។ ការផ្តន្ទាទោសសម្រាប់រូបអាសអាភាសនៅក្នុងសេចក្តីព្រាងច្បាប់នេះ ជាពិសេសការពិន័យជាប្រាក់ មានចំនួនច្រើនជាង ដោយការផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី ១ ខែ ទៅ ៦ ខែ និងពិន័យជាប្រាក់ចាប់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល។

## សេចក្តីសន្និដ្ឋាន

មជ្ឈមណ្ឌល ICNL មានក្តីសោមនស្សនឹងឱកាសរៀបរៀងអត្ថបទវិភាគលើសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាននេះ។ ការកែសម្រួលបញ្ហាដែលបានលើកឡើងនៅក្នុងអត្ថបទវិភាគនេះ នឹងធ្វើឱ្យសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មានមានអនុលោមភាពល្អប្រសើរជាងនេះស្របតាមច្បាប់អន្តរជាតិទាក់ទងនឹងសេរីភាពបញ្ចេញមតិ។ មជ្ឈមណ្ឌល ICNL នៅតែបើកទូលាយក្នុងការផ្តល់ជំនួយបច្ចេកទេស តាមដែលអាចធ្វើទៅបាន។ ចំពោះព័ត៌មានបន្ថែម ឬសំនួរណាមួយ សូមទាក់ទងមកក្រុមការងារសិទ្ធិឌីជីថលរបស់មជ្ឈមណ្ឌល ICNL យើងខ្ញុំតាមរយៈ digital@icnl.org។